អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# កូនជ្រូកទាំងបី
# Three little pigs

កែសម្រួលដោយ **TUKTUK**

រូបភាពដោយ និស្សិតនៃសកលវិទ្យាល័យ
Seinan Jo Gakuin ប្រទេសជប៉ុន





« កូនសម្លាញ់ទាំងបី ឥឡូវកូនធំៗអស់ហើយកូនៗត្រូវរៀនរស់នៅដោយខ្លួនឯង ព្រោះម៉ែមិនអាចចិញ្ចឹមកូនៗទាំងបីបានទៀតនោះទេ។ ម៉ែនឹងឱ្យប្រាក់ខ្លះដល់កូនៗ ដើម្បីធ្វើដំណើរតាមផ្លូវទៅរកកន្លែងសង់ផ្ទះរស់នៅដោយខ្លួនឯង » ម៉ែនិយាយ។



« បាទ! ម៉ែ » កូនជ្រូកទាំងបីឆ្លើយ។

កូនជ្រូកទីមួយនិងទីពីរបានសម្រេចចិត្តរស់នៅបែកគ្នា ប៉ុន្តែកូនជ្រូកទីបីមិនសប្បាយចិត្តទេ ព្រោះវាគិតថា ការរស់នៅជុំគ្នាគឺជាសាមគ្គីភាពដ៏រឹងមាំនិងមានសុវត្ថិភាព។



ថ្ងៃបន្ទាប់ កូនជ្រូកទាំងបីចាប់ផ្ដើមស្វែងរកទិញវត្ថុធាតុដើមនិងបោះទីតាំងសង់ផ្ទះរៀងៗខ្លួន។
កូនជ្រូកទីមួយបានសង់ផ្ទះពីចំបើង ព្រោះគិតថា អាចសន្សំប្រាក់បានខ្លះនិងងាយស្រួលសង់ទៀតផង។
វាបានសង់ផ្ទះរួចមុនគេ ហើយគិតថា ខ្លួនជាកូនជ្រូកដែលឆ្លាត។



កូនជ្រូកទីពីរសង់ផ្ទះអំពីឈើ ព្រោះផ្ទះឈើត្រដាក់និងសង់អស់ប្រាក់តិច។
វាគិតថា ហេតុអ្វីបានជាកូនជ្រូកទីមួយសង់ផ្ទះលឿនម្ល៉េះ?
ផ្ទះឈើរបស់វារឹងមាំជាងផ្ទះកូនជ្រូកទីមួយដែលសង់ពីចំបើង។



ចំណែកកូនជ្រូកទីបីគិតថា ត្រូវតែសង់ផ្ទះរឹងមាំមួយអំពីថ្ម ដើម្បីការពារសុវត្ថិភាព ទោះបីជាចំណាយពេលវេលាយូរនិងត្រូវដេកលើដីសិនក៏ដោយ។ បងៗរបស់វាបានសង់ផ្ទះរួចមុន ហើយបានសើចចំអកឱ្យកូនជ្រូកទីបី។កូនជ្រូកទីបីមិនខ្វល់ នៅតែបន្តសង់ផ្ទះរបស់វាដដែល។



ច្រើនថ្ងៃកន្លងផុតទៅ កូនជ្រូកទាំងបីរស់នៅយ៉ាងសុខសាន្ត។
ថ្ងៃមួយ ឆ្កែចចកឃើញកូនជ្រូកទាំងបី ហើយវានិយាយ



« អូ! កូនជ្រូកនោះមើលទៅគួរឱ្យចង់ស៊ីដល់ហើយ ខ្ញុំចង់ស៊ីពួកវាជាអាហារ។
ខ្ញុំឃ្លាន! ឃ្លានខ្លាំងណាស់! »



ឆ្កែចចកបានគោះទ្វារផ្ទះកូនជ្រូកទីមួយ « បើកទ្វារ! បើកទ្វារ! បើកទ្វារ! »
ដើម្បីសុំចូលក្នុងផ្ទះ តែកូនជ្រូកមិនព្រម។ កូនជ្រូកទីមួយនិយាយ « មុខឯងអាក្រក់ណាស់
មានពោមពេញមុខ ចង្កូមវែងៗគួរឱ្យខ្លាច ឆាប់ចេញទៅ »។



ឆ្កែចចកខឹងក៏បានបឺតខ្យល់ចូលពេញពោះ ហើយផ្លុំផ្ទះរបស់កូនជ្រូកទីមួយប៉ើងគ្មានសល់។



កូនជ្រូកទីមួយក៏រមៀលចូលក្នុងផ្ទះឈើរបស់កូនជ្រូកទីពីរ។ ឆ្កែចចកបានគោះទ្វារផ្ទះកូនជ្រូកទីពីរ « បើកទ្វារ! បើកទ្វារ! បើកទ្វារ! » ដើម្បីសុំចូលក្នុងផ្ទះ តែកូនជ្រូកមិនព្រម។



កូនជ្រូកទីពីរនិយាយ « មុខឯងអាក្រក់ណាស់ មានពោមពេញមុខ ចង្កូមវែងៗគួរឱ្យខ្លាច ឆាប់ចេញទៅ »។ ឆ្កែចចកខឹងក៏បានបឺតខ្យល់ចូលពេញពោះ ហើយផ្លុំផ្ទះឈើរបស់កូនជ្រូកទីពីរបើុងគ្មានសល់។



កូនជ្រូកទីមួយនិងកូនជ្រូកទីពីរបានរត់យ៉ាងលឿនចូលទៅក្នុងផ្ទះរបស់កូនជ្រូកទីបី។
កូនជ្រូកទីបីសួរ « តើមានរឿងអ្វីកើតឡើង ហេតុអ្វីបានជាបងៗភ័យខ្លាំងម្ល៉េះ? »
« ឆ្កែចចកបានផ្លុំផ្ទះរបស់ពួកយើងប៉ើងអស់ វានឹងមកផ្លុំផ្ទះរបស់ឯងឥឡូវដែរហើយ »។



« អូ! កុំបារម្ភណ៍អីបងៗ ឆ្កែចចកមិនអាចផ្លុំផ្ទះរបស់ខ្ញុំប៉ើងបានទេ »។



ឆ្កែចចកបានគោះទ្វារផ្ទះកូនជ្រូកទីបី « បើកទ្វារ! បើកទ្វារ! បើកទ្វារ! » ឆ្កែចចកផ្លុំផង រត់បុកទ្វារផង រហូតអស់កម្លាំង នៅតែមិនបើង ព្រោះកូនជ្រូកទាំងបីបានឈរទប់ទ្វារយ៉ាងស្វាហាប់។
« អូ! ខ្ញុំនឹងរកមធ្យោបាយ ដើម្បីស៊ីពួកឯងឱ្យទាល់តែបាន »។



ឆ្កែចចកឡើងលើដំបូលផ្ទះចូលតាមបំពង់ផ្សែង។
ចំណែកកូនជ្រូកទាំងបីបានពិភាក្សាគ្នា តើពួកគេគួរធ្វើដូចម្ដេច?



កូនជ្រូកទីបីនិយាយ « ខ្ញុំនឹងដុតភ្លើងដាំទឹក ដើម្បីឱ្យឆ្កែចចកធ្លាក់មក »។



ឆ្កែចចកបានរំកិលចូលតាមបំពង់ផ្សែងម្ដងបន្តិចៗ ក៏រអិលធ្លាក់ចូលក្នុងឆ្នាំងទឹកក្ដៅរលាកស្លាប់បាត់ទៅ។



កូនជ្រូកទីមួយនិយាយ « អរគុណប្អូនដែលបានជួយបង ពួកយើងត្រូវតែសាមគ្គីគ្នាទើបរឹងមាំ »។
រីឯកូនជ្រូកទីពីរ « មែនហើយ! បើគ្មានឯង បងក្លាយជាចំណីឆ្កែចចកបាត់ទៅហើយ »។



ការចេះជួយគ្នាក្នុងគ្រាមានអាសន្ន គឺជាសាមគ្គីភាពដ៏រឹងមាំ ហើយចាប់តាំងពីពេលនោះមក កូនជ្រូកទាំងបីក៏រស់នៅជាមួយគ្នាយ៉ាងមានក្ដីសុខ៕

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

TUKTUK

Rotary

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C)គឺជាអង្គការដែលមិនរកប្រាក់ចំណេញនិងផ្តោតលើការអប់រំកុមារតូចក្នុងប្រទេសកម្ពុជា។

អង្គការR4Cកំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើសាលាមត្តេយ្យរដ្ឋនិងមត្តេយ្យសហគមន៍។

អង្គការ R4C បានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្របទៅនឹងកម្មវិធីសិក្សារបស់ក្រសួងអប់រំនិងមានវគ្គបំប៉នលោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រ ដើម្បីទទួលបានធនធានបង្រៀន៖ https//rermork.org/

ទទួលបានព័ត៌មានបន្ថែម

មូលនិធិផ្តល់ដោយអង្គការTukTukនិងសមាគមរ៉ូតារីក្លឹប។

សៀវភៅរឿងនេះគូរដោយនិស្សិតនៃសកលវិទ្យាល័យ **Seinan Jo Gakuin** នៃប្រទេសជប៉ុន ។
ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកស្រី **Kristen Maree Sullivan** ដែលបានសហការជាមួយអង្គការដឹកនាំសម្របសម្រួលនិស្សិតស្ម័គ្រចិត្តបុគ្គលិកទាំងអស់នៅក្នុងអង្គការដោយក្តីមេត្តាធម៌ក្នុងការបង្កើតសៀវភៅនេះឡើង។

ទទួលបានគំនូរជីវចល

ទទួលបានធនធានបង្រៀន